# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ

## ក្រោមប្រធានបទ អំពីការរាប់បាត្រ និងការវេរចង្ហាន់

website ៖ www.hoksavann.org

*ថ្ងៃទី១៨ កញ្ញា ២០០៩*



*ប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ មានពាក្យប្រៀនប្រដៅដូចគ្នា ប៉ុន្តែពិធីកម្មក្នុងព្រះពុទ្ធសាសនាតែងតែមានលក្ខណៈផ្សេងគ្នា សូម្បីតែខ្មែរខ្លួនឯងក៏មិនទាន់មានឯកភាពក្នុងការអនុវត្តន៍ពិធីកម្មក្នុងព្រះពុទ្ធសាសនាដែរ ។*

### ***<u>ការរាប់បាត្រ</u>***

*ក្នុងការធ្វើបុណ្យទានផ្សេងៗ ពុទ្ធបរិស័ទខ្មែរច្រើននិយមរាប់បាត្រ ឬដាក់បាត្រ ។ នេះជាពិធីប្រសើរមួយដែរ ព្រោះពេលបួសភ្លាមព្រះឧបជ្ឈាយ៍ឲ្យនិស្ស័យ៨ គឺករណីយកិច្ចដែលត្រូវបំពេញ គឺអ្នកបួសត្រូវរស់នៅដោយដើរបិណ្ឌបាត្ររស់មួយជីវិត, នេះជាមូលបញ្ញត្តិគឺបញ្ញត្តិជាដំបូង ក្រោយមកមានពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លា និមន្តឆាន់ក្នុងពិធីបុណ្យផ្សេងៗ ទើបព្រះអង្គបញ្ញត្តិម្តងទៀត ហៅថាអនុប្បញ្ញត្តិ គឺបើគេនិមន្តអាចទទួលនិមន្តបាន មិនបាច់និមន្តបិណ្ឌបាត្រក៏បាន ។ ដើម្បីរក្សាបញ្ញត្តិជាដំបូង, បុណ្យធំៗ ពុទ្ធបរិស័ទខ្មែរបានរៀបគ្នាឈរជាជួរ ហើយនិមន្តព្រះសង្ឃឲ្យដើរបិណ្ឌបាត្រ ។ កន្លែងខ្លះគេដំកល់បាត្រលើអាសនៈមួយ ហើយគេនាំគ្នាយកបាយទៅរាប់បាត្រ ។ ត្រង់នេះមានបញ្ហាមួយ គឺពេលដែលពុទ្ធបរិស័ទកំពុងរាប់បាត្រ គេនិមន្តព្រះសង្ឃឲ្យសូត្រធម៌ ។ តើសូត្រឲ្យអ្នកណាស្តាប់ ឬសូត្រដើម្បីអ្វី ? ព្រោះនៅពេលដែលលោកសូត្រនោះ ពុទ្ធបរិស័ទនិយាយគ្នាអ៊ូអរ ស្ទើរបាត់សម្លេងព្រះសង្ឃសូត្រធម៌ ។ សកម្មភាពបែបនេះ ខ្វះការគោរពធម៌ ជាការពុំសមរម្យសោះ*

ឡើយ ។ បើយល់ថានិមន្តព្រះសង្ឃសូត្រធម៌នោះ គឺឲ្យលោកឧទ្ទិសឲ្យអ្នកស្លាប់ក៏មិនត្រូវដែរ ព្រោះការឧទ្ទិសនេះជាភារកិច្ចរបស់ម្ចាស់ទាន ពុំមែនកិច្ចរបស់ព្រះសង្ឃទេ ។ ព្រះសង្ឃជាបដិគ្គាហកៈ គឺជាអ្នកទទួលទាន ហើយលោកធ្វើបត្តានុមោទនាត្រេកអរចំពោះបុណ្យកុសលដែលពុទ្ធបរិស័ទបានធ្វើ ហើយលោកផ្សាយមេត្តាចិត្ត សូមឲ្យបំណងរបស់ពុទ្ធបរិស័ទបានសម្រេចតាមប្រាថ្នាតែប៉ុណ្ណោះ ។ សូម្បីលោកសូត្រធម៌ ក៏ពុំមែនសូត្រដើម្បីឲ្យអ្នកស្លាប់ស្តាប់ដែរ គឺសូត្រឲ្យអ្នកម្ចាស់ទានស្តាប់ ដើម្បីបង្កើតជាបុណ្យកុសល ចុះបើរវល់នាំគ្នាឡូឡានៅពេលលោកសូត្រនោះ តើមានត្រចៀកឯណាទៅស្តាប់ធម៌ ? ។

ដើម្បីឲ្យសមរម្យ ពុទ្ធបរិស័ទពុំគួរនិមន្តព្រះសង្ឃឲ្យសូត្រធម៌នៅពេលរាប់បាត្រ ដោយគ្មានការយកចិត្តទុកដាក់ស្តាប់នោះទេ គួររាប់បាត្រឲ្យចប់សព្វគ្រប់ ហើយនាំគ្នាមកអង្គុយឲ្យមានរបៀបរៀបរយ ទើបផ្តើមធ្វើពិធីមានមនស្ការព្រះរតនត្រ័យ សមាទានសីល ស្តាប់ព្រះសង្ឃស្វាធ្យាយន៍ធម៌ជាដើម ។

## <u>ការវេរចង្ហាន់</u>

ការវេរចង្ហាន់ជាពិធីកម្មមួយដ៏ល្អដែរ ។ រាល់ពេលធ្វើបុណ្យកុសល នៅវេលាថ្ងៃជិតត្រង់ ពុទ្ធបរិស័ទតែងធ្វើការវេរចង្ហាន់ ។ ការវេរចង្ហាន់ទុកដូចជាសុន្ទរកថាទូលព្រះសង្ឃឲ្យបានជ្រាប និងការតាំងចិត្តរបស់ខ្លួនក្នុងការបំពេញទាននេះ ។ ក្នុងការវេរនោះមានពាក្យថា ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ។ បានសេចក្តីថា របស់ដែលបានយកមកធ្វើទាននេះ ពុំមែនបានមកពីការលួចប្លន់ ឬសម្លាប់សត្វមកធ្វើបុណ្យទេ គឺបានមកប្រកបដោយធម៌ ។ ការពោលដូច្នេះ ដើម្បីកុំឲ្យព្រះសង្ឃមានសេចក្តីសង្ស័យអំពីចង្ហាន់ដែលយកមកប្រគេននេះ ព្រោះព្រះសង្ឃអាចឆាន់សាច់បានមិនត្រូវអាបត្តិ ដោយការបរិសុទ្ធដោយហេតុ៣យ៉ាងគឺ មិនបានឃើញគេសម្លាប់ មិនបានឮសត្វស្រែកពេលដែលគេសម្លាប់ និងមិនបានសង្ស័យថាគេសម្លាប់ដើម្បីខ្លួន ។ ក្នុងធម៌វេរនោះ បានបន្តទៀតថា ខ្ញុំព្រះករុណាសូមឧទ្ទិសកុសលជូនក្រុមគ្រួសារដែលចាកស្ថានទៅ មានមាតាបិតាជាដើម ។ នេះចាត់ជាការប្រគេនដោយវាចា និងបញ្ជាក់អំពីគោលបំណងនៃការធ្វើកុសលនេះ ។ ប៉ុន្តែបើប្រគេនមិនវេរក៏គ្មានទាស់អ្វីដែរ ព្រោះបុណ្យកុសលមានការធ្វើទានជាដើម កើតពីចេតនាលះ

បង់មច្ឆរិយៈក្នុងផ្លូវចិត្ត ។

ក្នុងការវេរនេះ មានបញ្ហាមួយដែលពុទ្ធបរិស័ទអនុវត្តតៗគ្នាមក ដោយសារសៀវភៅគិហិប្រតិបត្តិសរសេរថា ភិក្ខុ១អង្គវេរជាបុគ្គល ពី២អង្គទៅ៣អង្គវេរជាគណៈ ពី៤អង្គឡើងទៅទើបវេរជាសង្ឃ ។ នេះជាការភ័ន្តច្រឡំ ព្រោះការធ្វើទាននេះកើតពីចេតនាកម្ម ពុំមែនជាបញ្ញត្តិកម្មនេះ ។ ពាក្យថាធ្វើទានចំពោះព្រះសង្ឃមានន័យថា ក្រាលចិត្តទូទៅមិនចំពោះអង្គណាមួយ ។ ដូចជាដាក់បាត្រចំពោះព្រះសង្ឃ១អង្គដែលនិមន្តមកបិណ្ឌបាត្រ ដោយក្រាលចិត្តទូ-ទៅមិនចំពោះអង្គណា ជាព្រះសង្ឃនិមន្តមកពីទិសទាំង៤ ។ ការក្រាលចិត្តបែបនេះ ជាការធ្វើទានចំពោះព្រះសង្ឃហើយ មិនគិតពីចំនួនព្រះសង្ឃឡើយ ទោះបីភិក្ខុមានចំនួនប៉ុន្មានអង្គក៏ដោយ ។ ត្រង់ចេតនាបែបនេះ ភិក្ខុប៉ុន្មានអង្គក៏ចាត់ជាសង្ឃដែរ ។ មានអ្នកខ្លះនិមន្តចំពោះភិក្ខុមួយអង្គៗ ជាច្រើនវត្តមកផ្ដុំគ្នាធ្វើជាសង្ឃ ពុំអាចទៅជាសង្ឃកើតទេ ព្រោះមានចិត្តចំពោះបុគ្គលរួចទៅហើយ ។

ចំពោះព្រះសង្ឃ៤អង្គឬ៤អង្គឡើងទៅ ជាបញ្ញត្តិកម្ម ដែលព្រះពុទ្ធបានបញ្ញត្តិចំពោះព្រះសង្ឃ សំរាប់បំពេញកិច្ចការរបស់ព្រះសង្ឃដែលហៅថាសង្ឃកម្ម ។ ឧទាហរណ៍ ព្រះសង្ឃ៤អង្គអាចធ្វើឧបោសថសំដែងបាតិមោក្ខបាន ។ ព្រះសង្ឃ៥អង្គអាចធ្វើកឋិនកម្មបាន ។ ព្រះសង្ឃ២០អង្គក្នុងមជ្ឈិមប្រទេសដែលសម្បូណ៌ព្រះសង្ឃ អាចបំបួសកុលបុត្រជាភិក្ខុបានជាដើម ។ ហេតុដែលសង្ឃកម្មមានចំនួនព្រះសង្ឃតិចច្រើនជាងគ្នានេះ គឺយោលទៅតាមទំហំការងារ ។ បើការងារនោះមានទំហំតូច ត្រូវការព្រះសង្ឃក៏មានចំនួនតិច ដូចជាការធ្វើឧបោសថសំដែងបាតិមោក្ខជាដើម ។ បើការងារសំខាន់ខ្លាំង ត្រូវការព្រះភិក្ខុសង្ឃជាសមាជិកអង្គប្រជុំមានចំនួនច្រើនអង្គ ហើយត្រូវពិគ្រោះពិភាក្សាគ្នាឲ្យបានល្អិតល្អន់ ដូចជាការបំបួសកុលបុត្រជាដើម ។ ដូច្នេះបញ្ជាក់ថា ចំនួនព្រះសង្ឃចាប់ពី៤អង្គ និង៤អង្គឡើងទៅនោះ សំរាប់ធ្វើជាអង្គប្រជុំដើម្បីបំពេញកិច្ចការរបស់ព្រះសង្ឃ ពុំមែនសំរាប់សង្ឃទាននោះឡើយ ។ នេះជាបញ្ញត្តិកម្មដែលព្រះពុទ្ធបានបញ្ញត្តិ ដើម្បីឲ្យព្រះសង្ឃអនុវត្តសំរាប់បំពេញកិច្ចការរបស់ព្រះសង្ឃ ។ ចំណែកសង្ឃទាន គឺទានចំពោះព្រះសង្ឃនោះ គឺ

ចេតនាកម្ម គឺជាចេតនារបស់អ្នកធ្វើទានក្រាលចិត្តទូទៅមិនចំពោះភិក្ខុអង្គណាមួយ ។ ព្រះពុទ្ធមិនបានសំដែងថា ធ្វើទានឲ្យកើតជាសង្ឃត្រូវតែមានភិក្ខុចំនួនប៉ុណ្ណោះប៉ុណ្ណោះឡើយ ។ ដោយការភ័ន្តច្រឡំ បញ្ញត្តិកម្មរបស់សង្ឃកម្មមកធ្វើជាចេតនាកម្មរបស់សង្ឃទាននេះហើយ បានជាសៀវភៅគិហិប្រតិបត្តិសរសេរដូចបានពោលមកហើយ ។ ពុទ្ធសាសនាបានបើកសិទ្ធិសេរីភាព ទោះបីអ្នកធ្វើទានដោយការស្រឡាញ់ពេញចិត្តក្តី ដោយក្រាលចិត្តទូទៅដែលហៅថាសង្ឃទានក្តី ក៏ស្រេចតែទឹកចិត្តពុទ្ធបរិស័ទធ្វើតាមសទ្ធារបស់គេ ។

ការវេរចំពោះព្រះសង្ឃនេះមានបញ្ហាមួយទៀត ដោយមានគ្រូអ្នកបង្រៀនធម៌ខ្លះពោលថា បើគេវេរចង្ហាន់ប្រគេនជាសង្ឃទាន ត្រូវព្រះសង្ឃធ្វើអបលោកនកម្ម គឺចាត់ព្រះសង្ឃមួយអង្គដែលឈ្លាសវៃឲ្យបែងចែកចង្ហាន់នោះជាបុគ្គលទើបឆាន់បាន ។ ដូចយើងបានពោលខាងដើមហើយថា សង្ឃក្នុងសង្ឃទានមានលក្ខណៈខុសគ្នាពីសង្ឃក្នុងសង្ឃកម្ម ។ សង្ឃក្នុងសង្ឃទានមិនគិតពីចំនួនភិក្ខុទេ ប៉ុន្មានអង្គក៏ដោយ ក៏អាចវេរជាសង្ឃបាន គឺសង្ឃក្នុងន័យក្រាលចិត្តទូទៅមិនចំពោះអង្គណាមួយ ។ គេអាចចាត់ភិក្ខុ១អង្គឲ្យបែងចែកចង្ហាន់បើចង្ហាន់នោះមានចំនួនមិនស្មើគ្នា ។ បើចង្ហាន់ដែលគេប្រគេននោះមានភាពស្មើគ្នាហើយ មិនចាំបាច់ធ្វើអបលោកនចែកគ្នាទៀតទេ ហើយគេវេរប្រគេនចំពោះព្រះសង្ឃដែលនិមន្តមកក្នុងពិធីបុណ្យនោះ ពុំមែនព្រះសង្ឃដទៃទៀតទេ ។០៚

❊ ❊

❊